# កញ្ចប់ឧបករណ៍

ស្តង់ដារពិការភាព
សំរាប់ការអប់រំ



# វិធីគាំទ្រ

ធនធាននេះជួយសិស្សដែលមានពិការភាពអោយចេះកសាងជំនាញ
លើការគាំទ្រអោយខ្លួនឯង
ហើយនិងណែនាំពីរបៀបជំរាបនិងដោះស្រាយបារម្ភជាមួយអ្នកផ្តល់
ការអប់រំរបស់គេ។

ធនធាននេះត្រូវបានបង្កើតរួមគ្នាដោយសិស្សនិងយុវជនដែលមានពិការភាព និងមាតាបិតា និងអ្នកថែរក្សារបស់គេ។

## អំពីធនធាននេះ

ធនធាននេះត្រូវបានទទួលមូលនិធិពីរដ្ឋាភិបាលអូស្ត្រាលី។
វាត្រូវបានបង្កើតដោយសិស្សនិងក្មេងដែលមានពិការភាពនិងមាតាបិតានិងអ្នកថែរក្សារបស់គេ
រួមនឹងជំនួយពី**កុមារនិងយុវជនពិការនៅអូស្ត្រាលី** (CYDA) ហើយនិង**សម្ព័ន្ធពិការភាពជាតិសាសន៍** (NEDA)។

កញ្ចប់ឧបករណ៍នេះផ្តល់ព័ត៌មានទូទៅតែប៉ុណ្ណោះ។
វាមិនប្រហែលជាមិនបង្ហាញពីរបៀបប្រើច្បាប់ដល់កាលៈទេសៈរបស់អ្នកទេ។ វាមិនផ្តល់ឱវាទច្បាប់ទេ។

រដ្ឋាភិបាលអូស្ត្រាលីទទួលស្គាល់ម្ចាស់ទឹកដីដើមនិងអ្នកថែរក្សាស្រុកទូទាំងប្រទេសអូស្ត្រាលី។
យើងទទួលស្គាល់ដល់ទំនាក់ទំនងដ៏និរន្តន៍ជាមួយដី ទឹក និងសហគមន៍របស់គេ។
យើងសូមគោរពដល់ពួកគេនិងដល់ពួកចាស់ទុំពីអតីតកាលនិងបច្ចុប្បន្នកាល។
យើងសូមគោរពដល់ការអនុវត្តផ្នែកវប្បធម៌ ព្រលឹងវិញ្ញាណ និងការអប់រំនៃជនអាបូរិជិនី និងពួកកោះTorres Straight.

## កំណត់សំគាល់ពីភាសា

ធនធាននេះប្រើភាសាបុគ្គលមុន (ឧ. សិស្សដែលមានពិការភាព)។ ប៉ុន្តែវិធីនេះមិនសមនឹងមនុស្សគ្រប់រូប ហើយមនុស្សជាច្រើនចូលចិត្តភាសាអត្តសញ្ញាណមុន (ឧ. សិស្សពិការ)។

វាសំរេចទៅលើបុគ្គលម្នាក់ៗ ដែលគេជ្រើសរើសសំគាល់ខ្លួនដោយរបៀបណានោះ។ យើងសូមលើកទឹកចិត្តអ្នកអោយសួរគេថាគេចូលចិត្តអ្វី។ យើងក៏ទទួលស្គាល់ប្រវត្តិសាស្ត្រដ៏ជ្រាលជ្រៅដែលនៅពីក្រោយពាក្យទាំងនេះដែរ។

## ធនធានបន្ថែម

នេះគឺផ្នែកមួយនៃធនធានមួយក្រុម។ អ្នកអាចរកឃើញនៅក្នុងវែបសៃត៍របស់ក្រសួងអប់រំនៃរដ្ឋាភិបាលអូស្ត្រាលី ឬដោយស្កេនកូដ QR.

ស្កេនកូដ QR

ធនធាននេះក៏មានជា Easy Read, Auslan និងភាសាផ្សេងៗមួយចំនួនទៀត។ អ្នកអាចចូលមើលសំណេរទាំងនោះនៅវែបសៃត៍របស់ក្រសួងអប់រំនៃរដ្ឋាភិបាលអូស្ត្រាលី ឬដោយស្កេនកូដ QR.

***កំណត់សំគាល់មាតិកា:*** *ធនធាននេះនិយាយពីការរើសអើងនិងការប្រកាន់។ មានឧទាហរណ៍ពីគំនិត និងភាសាអវិជ្ជមាន។ សូមទូរស័ព្ទមក Lifeline តាមលេខ* ***13 11 14*** *ឬផ្ញើសារមកលេខ* ***0477 13 11 14*** *សំរាប់ការជួយគាំទ្រ។*

## កញ្ចប់ឧបករណ៍នេះសំរាប់អ្នកណា

កញ្ចប់ឧបករណ៍នេះគឺសំរាប់អ្នកជាសិស្សដែលមានពិការភាព។

## កញ្ចប់ឧបករណ៍នេះសំរាប់អ្វី

កញ្ចប់ឧបករណ៍នេះគឺសំរាប់ជួយអ្នកអោយ**គាំទ្រ**អោយខ្លួនឯងទល់នឹង**ស្ថាប័នអប់រំ**របស់អ្នក។

**ការគាំទ្រ**មានន័យថា ការពារសិទ្ធិ ឬសេចក្តីត្រូវការជំនួសអ្នកណាម្នាក់។

### និយមន័យ: ស្ថាប័នអប់រំ

ស្ថាប័នអប់រំ ជាអង្គការមួយដែលផ្តល់ការអប់រំឬការហ្វឹកហ្វឺន។ នេះអាចជា:



សាលា



សកលវិទ្យាល័យ



សាលាអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈ (VET)

## កញ្ចប់ឧបករណ៍នេះនិយាយពីអ្វីខ្លះ

កញ្ចប់ឧបករណ៍នឹងបង្ហាញពីរបៀបគាំទ្រសំរាប់ខ្លួនអ្នកគ្រប់ជំហាននីមួយៗ។ វានិយាយអំពី:


- ការគាំទ្រអោយខ្លួនឯង (ទ. 2)
- ច្បាប់រើសអើងពិការភាពអូស្ត្រាលី (ទ. 2)
- សិទ្ធិអ្នកមានអ្វីខ្លះ (ទ. 3)
- ចុះបើស្ថាប័នអប់រំមិនដើរតាម DSE? (ទ. 4)
- គាំទ្រសំរាប់ខ្លួនឯង (ទ. 4)
- កត់ដំណើរគាំទ្ររបស់អ្នក (ទ. 6)
- កន្លែងទទួលជំនួយនិងព័ត៌មាន (ទ. 18)

# ការគាំទ្រខ្លួនឯង

ការគាំទ្រខ្លួនឯងមានន័យថាអ្នកៈ

- ការពារសំរាប់ខ្លួនឯងនិងអ្វីដែលសំខាន់ដល់អ្នក
- ដឹងសិទ្ធិនិងការពារសិទ្ធិរបស់អ្នក
- សូមនូវអ្វីដែលអ្នកត្រូវការ
- ប្រាប់គេនូវអ្វីដែលអ្នកគិតនិងមានអារម្មណ៍
- ដឹងធ្វើការជ្រើសរើសនិងសំរេចចិត្តអំពីជីវិតរបស់អ្នក
- ទៅរកជំនួយបើអ្នកត្រូវការ។

# ច្បាប់រើសអើងពិការភាពអូស្ត្រាលី

សិស្សទាំងអស់ដែលមានពិការភាពក្នុងប្រទេសអូស្ត្រាលី ត្រូវបានការពារដោយ ***ច្បាប់រើសអើងពិការភាព1992*** (DDA) និង ***ស្តង់ដារពិការភាពសំរាប់ការអប់រំ2005*** (DSE)។ អ្នកផ្តល់ការអប់រំទាំងអស់ត្រូវអនុលោមតាម DDA និង DSE ។

## និយមន័យៈ ច្បាប់រើសអើងពិការភាព1992 (DDA)

ច្បាប់ DDA ជាច្បាប់មួយសំរាប់ជនគ្រប់រូបនៅប្រទេសអូស្ត្រាលី។
វាការពារមិនអោយមានការរើសអើងដោយសារពិការភាពរបស់គេ។

## និយមន័យៈ ស្តង់ដារពិការភាពសំរាប់ការអប់រំ 2005 (DSE)

ច្បាប់ DSE ជាច្បាប់មួយចំនួនដែលស្ថិតនៅក្រោម DDA។ ច្បាប់ទាំងនេះបញ្ជាក់កាតព្វកិច្ចរបស់អ្នកផ្តល់ការអប់រំ។
ច្បាប់ DSE ប្រាប់អ្នកផ្តល់ការអប់រំទាំងឡាយថាគេត្រូវធ្វើយ៉ាងណាដើម្បីគាំទ្រសិស្សដែលមានពិការភាព។

ស្ថាប័នអប់រំអាចធ្វើតាម DSE ដោយធ្វើការផ្លាស់ប្តូរដែលជួយគាំទ្រសិស្សដែលមានពិការភាព ដើម្បីអោយគេចូលរៀនលើ**មូលដ្ឋានដូចគ្នា**នឹងមិត្តស្រករពួកគេដែរ។

ការផ្លាស់ប្តូរទាំងនេះហៅថាការកែសំរួលសមហេតុផល។ វាអាចជា:

- មនុស្ស (ឧ. បុគ្គលិកជំនួយ)
- ឧបករណ៍ (ឧ. គ្រឿងអាន)
- ការផ្លាស់ប្តូរដល់របៀបធ្វើអ្វីមួយ (ឧ. ការឈប់សំរាក)។

ជាទូទៅអ្នកផ្តល់ការអប់រំត្រូវធ្វើការផ្លាស់ប្តូរលុះត្រាណាវាបណ្តាលអោយមានភាពលំបាកហួសហេតុផល។

អ្នកអាចស្វែងយល់ថែមអំពី DSE និងពាក្យសំខាន់ៗដូចជា 'មូលដ្ឋានដូចគ្នា',
'ការកែសំរួលសមហេតុផល' និង 'ភាពលំបាកហួសហេតុផល' ក្នុងធនធានរបស់យើង:
ពន្យល់ស្តង់ដារពិការភាពសំរាប់ការអប់រំ។

## សិទ្ធិអ្នកគឺមានអ្វីខ្លះ

អ្នកមានសិទ្ធិដូចសិស្សដែលគ្មានពិការភាព ដើម្បីនឹង:



ដាក់ពាក្យសុំ ត្រូវគេទទួលយក និងចុះឈ្មោះចូលរៀនក្នុងស្ថាប័នអប់រំណាមួយ



ចូលរួមក្នុងគ្រប់ផ្នែកមេរៀនឬកម្មវិធីអប់រំរបស់អ្នក



រួមចំណែកក្នុងបទពិសោធន៍រៀនសូត្រ



រៀនក្នុងបរិស្ថានសុខសាន្ត ផុតពីការរើសអើង ការយាយី និងការធ្វើបាប



ប្រើសេវាកម្មជំនួយ ឧ. អ្នកផ្តល់ឱវាទប្រចាំសាលា

ស្ថាប័នអប់រំរបស់អ្នក**ត្រូវ**ធ្វើតាម DSE ដើម្បីជួយគាំទ្រសិស្សដែលមានពិការភាព។

អ្នកអាចស្វែងយល់ថែមទៀតអំពីការយាយីនិងការធ្វើបាបក្នុងធនធានរបស់យើង:
ពន្យល់ស្តង់ដារពិការសំរាប់ការអប់រំ។

# ចុះបើស្ថាប័នអប់រំរបស់ខ្ញុំមិនធ្វើតាម DSE?

បើអ្នកបារម្ភឬគិតថាស្ថាប័នអប់រំរបស់អ្នកមិនអនុលោមតាម DSE នោះអ្នកអាចពិគ្រោះការនេះជាមួយគេបាន។ អ្នកគួរធ្វើអោយបានលឿនតាមអាចធ្វើបាន។ នេះជាការគាំទ្រអោយខ្លួនឯង។

ពេលអ្នកធ្វើការនេះ អ្នកគួរ:

- *សុំនូវអ្វីដែលអ្នកត្រូវការ។* មិនត្រូវអនុញ្ញាតអោយអ្នកណាមកធ្វើអោយអ្នកអៀនខ្មាស ឬមកដាក់សម្ពាធអោយអ្នកទទួលយកអ្វីដែលតិចតួចជាងនោះឡើយ។
- សូមគិតអោយបានទូលំទូលាយ។ ចូរគិតអំពីចក្ខុវិស័យសំរាប់ការអប់រំរបស់អ្នក ថាតើវាជាអ្វី។
- សូមមើលថែរក្សាខ្លួនឯង។ សូមរៀបចំទីពឹងផ្អែកដែលអ្នកត្រូវការ ដូចជាមិត្តម្នាក់ ឬអ្នកជួយគាំទ្រណាម្នាក់។

# គាំទ្រអោយខ្លួនឯង

នៅពេលអ្នកគាំទ្រ អ្នកចង់អោយអ្នកដទៃយល់ពីទស្សនៈរបស់អ្នក។ នេះអាចពិបាកបើគេមានទស្សនៈ ឬអាទិភាពខុសពីអ្នក។

ដើម្បីជួយត្រៀមសំរាប់ការសន្ទនាទាំងនេះ សូមគិតអំពី:

- អ្នកបារម្ភពីអ្វីខ្លះ ?
- អ្វីទៅជាគោលដៅរបស់អ្នក ?
- មានដំណោះស្រាយអ្វីខ្លះ ?
- អ្វីខ្លះដែលចរចារមិនបាន ?
- អ្វីខ្លះដែលចរចារបាន ?

បន្ទាប់មក អ្នកនឹងរកដំណោះស្រាយជាមួយគ្នា។

## យកតំណែងរបស់ខ្លួន

វិធីម្យ៉ាងក្នុងការគិតថាខ្លួនជាអ្នកគាំទ្រគឺ'ការយកតំណែងរបស់ខ្លួន'។
នេះមានន័យថាអ្នកមានចំណែកក្នុងការសន្ទនាដែលប៉ះពាល់ដល់អ្នកនិងជីវិតអ្នក។
នេះរាប់ទាំងការសន្ទនាជាមួយអ្នកផ្តល់ការអប់រំរបស់ អ្នក។
គេគួរប្រព្រឹត្តមកអ្នកក្នុងឋានៈដែលមានភាពស្មើគ្នា ហើយអោយតំលៃដល់មតិរបស់អ្នក។

យើងទាំងអស់គ្នាមានអ្វីមួយក្នុងជីវិតយើងដែលអាចធ្វើអោយស្រួលឬពិបាកនឹងធ្វើការនេះ។

កន្លែងយើងនៅ ធ្វើការ និងរស់ធំឡើងសុទ្ធតែប៉ះពាល់ដល់ការគិតអំពីការគាំទ្រអោយខ្លួនឯង។
ក៏ដូចគ្នានឹងរឿងភេទ ផ្លូវភេទ វប្បធម៌ និងសាសនាដែរ។ វាអាចប៉ះពាល់ដល់របៀបអ្នកដទៃតបមកអ្នក។

សំខាន់គឺត្រូវដឹងថាៈ

- អ្នកគួរមានមោទនភាពនឹងពិការភាពរបស់អ្នក មិនមែនខ្មាសអៀនទេ។ អ្នកមិនគួរមានអារម្មណ៍មិនល្អក្នុងការសុំនូវអ្វីដែលអ្នកត្រូវការឡើយ។
- អ្នកត្អូញត្អែបានពេលមានអ្វីដែលមិនត្រូវ។ អ្នកមានសិទ្ធិដល់ការអប់រំដែលប្រកបដោយយុត្តិធម៌។
- អ្នកផ្តល់ការអប់រំរបស់អ្នកត្រូវអនុលោមតាម DSE ។ នេះជាច្បាប់អូស្ត្រាលី។ បើគេមិនធ្វើតាមទេ នោះអ្នកអាចសុំអោយគេធ្វើតាមបាន។ គេមិនត្រូវធ្វើទណ្ឌកម្មអ្នកចំពោះការនេះឡើយ។
- ការចរចារមិនងាយស្រួលរហូតទេ។ វាអាចញ៉ាំងអោយមានគំនិតមិនស្រួលឬមនោសញ្ចេតនាមិនស្រួល។ បើអ្នកមានអារម្មណ៍មិនស្រួលឬទល់ច្រក អ្នកអាចរកជំនួយបាន។ សូមមើល កន្លែងទទួលជំនួយនិងព័ត៌មាន (ទ. 18).



# កត់ដំណើរគាំទ្ររបស់អ្នក

មុននឹងអ្នកជំរាបគេពីបារម្ភ សូមមើលដំណើរថ្លែងតំអូញសំរាប់អ្នកផ្តល់ការអប់រំរបស់អ្នក។ ធ្វើដូចនេះនឹងជួយអោយអ្នកដឹងថានឹងត្រូវនិយាយជាមួយអ្នកណា។ អ្នកអាចរកព័ត៌មាននេះនៅវេបសៃត៍នៃស្ថាប័នអប់រំរបស់អ្នក ឬអ្នកអាចសួរគេសុំមួយច្បាប់ក៏បាន។ យកល្អគួរចំណាយពេលវេលាខ្លះៗដើម្បីរៀបចំមុននឹងជំរាបពីបារម្ភឬតំអូញ។

ជំហានខាងក្រោមនេះនឹងជួយដល់ដំណើរគាំទ្ររបស់អ្នក។ គេនឹងជួយអ្នកអោយសំរេចចិត្តថាត្រូវទាក់ទងអ្នកណា ហើយនិងតាមលំដាប់ណា។

ជំហានទាំងនេះគឺ:

1. ធ្វើការសន្ទនាជាមួយស្ថាប័នអប់រំរបស់អ្នក។
2. ជំរាបបារម្ភរបស់អ្នកទៅអ្នកគ្រប់គ្រងឬអង្គការដែលគ្រប់គ្រងស្ថាប័នអប់រំ។
3. តួញត្អែទៅអាជ្ញាធរមួយទៀត។

បើអ្នកមិនពេញចិត្តនឹងការតបឆ្លើយក្នុងជំហានណាមួយ នោះអ្នកអាច**លើក**បារម្ភអ្នកទៅថ្នាក់លើ។

## និយមន័យ: លើកទៅថ្នាក់លើ

ពេលអ្នកលើកបារម្ភទៅថ្នាក់លើ នោះមានន័យថាអ្នកយកវាទៅមួយជំណាក់ទៀត។

ឧទាហរណ៍ នេះអាចជាលើកទៅសមាជិកបុគ្គលិកណាម្នាក់ដែលចំណានជាង ឬទៅ**អង្គការផ្នែកតំអូញ**។

១. អ្នកសំរេចចិត្តថានឹងឈប់អ៊ីមេលគ្រូអ្នក ហើយនឹងនិយាយទៅអ្នកចាត់ចែងថ្នាក់របស់អ្នកវិញ។

## និយមន័យ: អង្គការផ្នែកតំអូញ

អង្គការផ្នែកតំអូញជាអង្គការឯករាជ្យមួយដែលចាត់ការអំពីបារម្ភនិងតំអូញ។

## 1) ធ្វើការសន្ទនាជាមួយស្ថាប័នអប់រំរបស់អ្នក

ជំហាននេះគឺងាយៗ អាចដូចជាការផ្ញើអ៊ីមេលមួយទៅគ្រូរបស់អ្នក ឬការនិយាយបន្ទាប់ពីវគ្គសិក្សា។ ឬអ្នកប្រហែលត្រូវការប្រជុំដើម្បីពិគ្រោះគ្នាអោយបានពិស្តារថែមទៀត។

អ្នកប្រហែលត្រូវការនិយាយទៅពួកគេពីរបីដងដើម្បីរកដំណោះស្រាយដែលស័ក្តិសមសំរាប់គ្រប់គ្នា។ អ្នកក៏ប្រហែលត្រូវសាកល្បងធ្វើអ្វីផ្សេងៗដើម្បីរកមើលថាអ្វីហុចផលបានល្អបំផុតសំរាប់អ្នក។

លទ្ធផលដ៏ល្អបំផុតបានសំរេចនៅពេលសិស្ស គ្រូ មាតាបិតា និងអ្នកថែរក្សាធ្វើការជាមួយគ្នា។

## គន្លឹះជួយសន្ទនាជាមួយស្ថាប័នអប់រំរបស់អ្នក

1. ត្រូវដឹងសិទ្ធិរបស់អ្នក ហើយថាវាមានន័យអ្វីខ្លះសំរាប់ស្ថានភាពរបស់អ្នក។ សូមមើល ពន្យល់ស្តង់ដារពិការភាពសំរាប់ការអប់រំ

2. សូមគិតដល់អ្នកម្នាក់ទៀត និងអ្វីដែលអ្នកដឹងអំពីគាត់។ តើគាត់គិតអ្វីខ្លះពីស្ថានភាពនេះ? តើអ្នកគិតថាគាត់នឹងប្រតិកម្មយ៉ាងណាខ្លះ? តើអ្វីទៅជាវិធីត្រឹមត្រូវសំរាប់ចាប់ផ្តើមសន្ទនាជាមួយគាត់? (ឧ. តើអ្នកចង់ផ្តោតទៅលើសិទ្ធិ ឬការចង់ដឹង?)

3. ត្រៀមសំណើជណ្តើរយន្តរបស់អ្នកអោយបានរួចរាល់សិន។ នេះជាសុន្ទរកថាដ៏ខ្លីមួយដែលអ្នកអាចថ្លែងដល់អ្នកណាម្នាក់បើអ្នកមានតែពេលខ្លីប៉ុណ្ណោះ (ឧ. បើអ្នកឡើងជណ្តើរយន្ត!) សំណើរបស់អ្នកនឹងរៀបរាប់ពីគោលចំណុចសំខាន់ៗ។

4. ហ្វឹកហាត់សិន។ អ្នកអាចសមជាមួយមិត្តម្នាក់សិនក៏បាន។

5. យកភស្តុតាងមកផងបើអ្នកគិតថាវានឹងជួយ ឧ. នេះអាចជាលិខិតមកពីអ្នកជំនាញសុខភាពម្នាក់។

6. សូមមើលថែខ្លួនឯង ហើយនៅអោយបានសុខ។ តើអ្នកត្រូវការអ្នកណាម្នាក់នៅជាមួយដើម្បីជាជំនួយឬជាសាក្សីឬទេ? តើអ្នកមានអារម្មណ៍ធូរស្បើយជាងបើនិយាយតាមទូរស័ព្ទឬតាមអ៊ីមេល?

7. ត្រៀមការសន្ទនាក្នុងចិត្តសិន។ តើអ្នកចង់មានអារម្មណ៍ពោរពេញដោយថាមពលឬ? ស្ងប់ហើយនឹងធឹងឬ? តើមានអ្វីអាចជួយអោយអ្នកមានអារម្មណ៍បែបនេះ? អាចជាភ្លេង មិត្ត ឬពេលវេលាស្ងាត់តែឯង។

8. ចូរកត់អ្វីដែលកើតឡើងទុក។ អ្នកអាចកត់លើក្រដាស ឬអាត់ក្នុងទូរស័ព្ទក៏បាន។ សូមការអនុញ្ញាតជាមុនសិនមុននឹងអាត់សំឡេងអ្នកណាម្នាក់។

9. សូមពន្យល់ថាអ្នកមានអារម្មណ៍យ៉ាងណា។ អ្នកខ្លះយល់ដល់អារម្មណ៍របស់អ្នកជាងបទពិសោធន៍របស់ អ្នក។ ជាជាងនិយាយថា 'ខ្ញុំកំពុងពិសោធ ក' អ្នកអាចនិយាយថា 'ការពិសោធ ក ធ្វើអោយខ្ញុំមានអារម្មណ៍ ខ'។ ឧ. 'មិនបានចូលថ្នាក់រៀនធ្វើអោយខ្ញុំមានអារម្មណ៍ថប់និងលិចលង់'។

10. ចូរប្រើពាក្យ 'ខ្ញុំ' ។ អ្នកនិយាយសំរាប់តែខ្លួនអ្នកបានហើយ មិនមែនសំរាប់គ្រប់គ្នាដែលមានពិការភាពដូចអ្នកឡើយ។ នេះនឹងធ្វើអោយអ្នកនោះយល់ស្ថានភាពរបស់អ្នក។

## ជំរាបបារម្ភទៅអ្នកណា

អ្នកជំរាបបារម្ភរបស់អ្នកទៅអ្នកណានោះគឺអាស្រ័យទៅលើបារម្ភរបស់អ្នកស្តីពីអ្វី។ តើវាស្តីពីមេរៀនមួយឬ?

តើវាស្តីពីបទពិសោធន៍រៀនសូត្រទាំងមូលរបស់អ្នកឬ? បារម្ភរបស់អ្នកធំប៉ុណ្ណា

នោះភាពញាំុងអោយអ្នកជំរាបដល់អ្នកជំនាញម្នាក់ក៏ធំប៉ុណ្ណោះដែរ។

តារាង 'ត្រូវទាក់ទងនរណា' នឹងជួយអោយអ្នកសំរេចចិត្តៈ

- ត្រូវទាក់ទងអ្នកណាមុន
- ត្រូវទាក់ទងអ្នកណាមុន បើអ្នកនោះមិនអាចធ្វើការផ្លាស់ប្តូរដែលអ្នកត្រូវការ ឬដោះស្រាយបារម្ភរបស់អ្នកមិនបាន។

អ្នកអាចរំលងទៅថ្នាក់បន្ទាប់បានបើមានអារម្មណ៍កក់ក្តៅជាងពេលធ្វើដូច្នេះ។

## ត្រូវទាក់ទងនរណា

| **ឧទាហរណ៍នៃស្ថាប័នអប់រំ** | **អ្នកនៅក្នុងថ្នាក់រៀន** *អ្នកស្គាល់អ្នកហើយអាចធ្វើការផ្លាស់ប្តូរ ផ្ទាល់* | **អ្នកចាត់ចែងការកែសំរួល** *អាចស្នើអោយផ្លាស់ប្តូរជំនួសអ្នក* | **អ្នកមើលខុសត្រូវ** *មានអំណាចផ្លាស់ប្តូរលើផ្នែកច្រើន* |
|---|---|---|---|
| បឋមសិក្សាឬមធ្យមសិក្សា | ឧ. គ្រូឬបុគ្គលិកជំនួយ | ឧ. អ្នកចាត់ចែងប្រចាំថ្នាក់ ប្រធានជំនួយការរៀន ឬអ្នកផ្តល់ឱវាទ | ឧ. ចាងហ្វាង |
| *សាលាអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (រាប់ទាំងTAFE )* | ឧ. គ្រូឬគ្រូបង្វឹក | ឧ. ប្រធានកម្មវិធី អ្នកផ្តល់ឱវាទផ្នែកសមធម៌ និងលទ្ធភាពទទួលសំរាប់សិស្ស | ឧ. នាយកប្រតិបត្តិ ប្រធានសាលា |
| *សាកលវិទ្យាល័យ* | ឧ. គ្រូបង្រៀនគួរឬគ្រូបង្រៀន | ឧ.ភ្នាក់ងារទំនាក់ទំនងពិការភាព អ្នកចាត់ចែងមេរៀន | ឧ. សកលវិទ្យាធិការ ប្រធានសាលា |

## ករណីសិក្សា: មិល្លី

មិល្លីជាសិស្សថ្នាក់ទី 10។ រាល់ដើមឆ្នាំ មិល្លីនិងឪពុកម្តាយគាត់មកជួបប្រធានកំរិតថ្នាំ។
ពួកគេពិគ្រោះអំពីការកែសំរួលដែលមិល្លីត្រូវការ ហើយយល់ស្របនឹងគំពោងអប់រំមួយ។
ការនេះបញ្ជាក់ដល់គ្រូទាំងអស់របស់មិល្លីថាគាត់ត្រូវការជំនួយអ្វីខ្លះក្នុងថ្នាក់រៀន។

មានសប្តាហ៍មួយ គ្រូវិទ្យាសាស្ត្ររបស់មិល្លីក៏មិនបានមកព្រោះឈឺ។ សាលាក៏យកគ្រូជំនួសមក។
ធម្មតាមិល្លីអាចសំរាកហើយចេញពីថ្នាក់ពេលត្រូវការ។
គាត់អាចប្រើការវិនិច្ឆ័យរបស់គាត់ហើយមិនត្រូវការសួរមុនទេ។
ពេលនេះគ្រូជំនួសបញ្ឈប់គាត់មិនអោយចេញពីថ្នាក់រៀន។ នេះធ្វើអោយមិល្លីមានអារម្មណ៍ថប់
និងមិនសប្បាយចិត្ត។

មិល្លីក៏និយាយជាមួយគ្រូជំនួយបន្ទាប់ពីថ្នាក់។ គាត់ក៏សុំទោស
ហើយសូមគំពោងអប់រំរបស់មិល្លីពីប្រធានកំរិតថ្នាំ។ មិល្លីនិងឪពុកម្តាយរបស់គាត់ក៏សរសេរអ៊ីមេលទៅសាលាដែរ។
ដើម្បីកុំអោយការនេះកើតឡើងម្តងទៀត
គេសូមអោយគំពោងអប់រំរបស់មិល្លីត្រូវប្រគល់ទៅគ្រូទាំងអស់មុននឹងចាប់ផ្តើមមេរៀនជាមួយមិល្លី។

## រៀបចំសំរាប់ការប្រជុំ

1. សុំជួប។
2. កត់ក្នុងបញ្ជីនូវអ្វីដែលអ្នកចង់ពិគ្រោះក្នុងការប្រជុំ។
3. រកជំនួយពីអ្នកណាម្នាក់ដែលអ្នកទុកចិត្ត
   ដូចជាសមាជិកក្រុមគ្រួសារឬមិត្តភក្តិ។

## ពេលប្រជុំ

1. សូមប្រាប់គេថា:
   a) អ្នកត្រូវការអ្វីខ្លះ ឬមានបារម្ភអ្វីខ្លះ
   b) បញ្ហាប៉ះពាល់អ្នកយ៉ាងណា
   c) បានធ្វើអ្វីខ្លះហើយ
   d) អ្នកចង់អោយមានអ្វីកើតឡើង។
2. គូសបញ្ជីកាលបានសំរេចហើយ។
3. កត់ត្រាទុក។
4. យល់ស្របនឹងគំពោងសំរាប់ការផ្លាស់ប្តូរ:
   a) តើនឹងមានអ្វីកើតឡើង ?
   b) តើអ្នកណានឹងធ្វើវា ?
   c) តើនឹងកើតឡើងនៅពេលណា ?
5. តាមសួរជាមួយអ្នកដែលនឹងធ្វើការផ្លាស់ប្តូរ។

## បន្ទាប់ពីប្រជុំ

1. ផ្ញើអ៊ីមេលទៅគ្រប់គ្នាដើម្បី:
   a) អរគុណគេ
   b) ជំរាបអ្វីដែលកើតឡើងនៅក្នុងការប្រជុំ និងជំរាបអ្វីជាគំពោង។
2. រក្សាការទាក់ទងគ្នា។
3. គោរពពេលវេលារបស់គេ។
4. ឆែកមើលក្រែងលោការផ្លាស់ប្តូរ
   a) ត្រូវបានធ្វើហើយ
   b) កំពុងមានដំណើរការ។

បើក្តីមិនគ្រាន់បើជាងមុនទេ អ្នកអាចទៅនិយាយជាមួយអ្នកដែលជំនាញជាងនេះ។
ឬក៏យកបារម្ភអ្នកឡើងទៅថ្នាក់បន្ទាប់ទៀតក៏បាន។

## សំរេចចិត្តនឹងលើករឿងទៅលើ

គ្រប់ស្ថានភាពគឺខុសគ្នា ដូច្នេះមិនមានចំឡើយងាយទេថាពេលណាត្រូវដំរាបបារម្ភអ្នកទៅលើ។

ដើម្បីជួយអោយអ្នកសំរេចចិត្ត អ្នកអាចៈ

- ឆែកមើលថាតើអ្នកមានអារម្មណ៍យ៉ាងណា (ឧ. គ្មានគេស្តាប់ គេមិនគោរព គេបដិសេធ)
- គិតអំពីអ្វីដែលអ្នកចង់អោយកើតឡើង
- ពិគ្រោះស្ថានភាពជាមួយអ្នកដែលអ្នកទុកចិត្ត (ឧ. មិត្ត គ្រួសារ អ្នកអោយឱវាទ

សញ្ញាដែលអ្នកអាចលើករឿងទៅលើមានដូចជាៈ

- អ្នកមិនអាចយល់ស្របជាមួយស្ថាប័នអប់រំរបស់អ្នក។
- ស្ថាប័នអប់រំមិនបានធ្វើតាមពេលកំណត់ នូវអ្វីដែលអ្នកត្រូវការអោយគេធ្វើ ឧ. (គេបានយល់ស្របថានឹងពង្រីកទំហំអក្សរនៃសន្លឹកកិច្ចការក្នុងរយៈពេលមួយសប្តាហ៍។ មួយខែក្រោយមក ឥតមានអ្វីកើតឡើង។)
- ស្ថាប័នអប់រំនិយាយថា វាមិនមែនជាការងាររបស់គេទេដែលត្រូវធ្វើតាមសំណូមពររបស់អ្នក។
- អ្នកមិនពេញចិត្តនឹងលទ្ធផលពីស្ថាប័នអប់រំ។

## 2) យកបារម្ភរបស់អ្នកទៅអ្នកគ្រប់គ្រង ឬអង្គការដែលគ្រប់គ្រងស្ថាប័នអប់រំរបស់អ្នក

បើស្ថាប័នអប់រំរបស់អ្នកមិនអាចដោះស្រាយបារម្ភរបស់អ្នកទេ នោះអ្នកប្រហែលជាត្រូវលើករឿងឡើងទៅថ្នាក់លើ។ នេះមានន័យថាលើកយកបារម្ភរបស់អ្នកទៅអ្នកគ្រប់គ្រង ឬអង្គការដែលគ្រប់គ្រងស្ថាប័នអប់រំរបស់អ្នក។ ជួនកាលគេហៅថាអាជ្ញាធរអប់រំ។ នេះអាចជាក្រសួងអប់រំរដ្ឋឬអនុរដ្ឋឬក្រុមប្រឹក្សាភិបាលសាកលវិទ្យាល័យ។ ឬក៏អាចជាអង្គការផ្នែកតំអូញ - ឧ. សាលាក្រៅពីរដ្ឋក្នុងរដ្ឋឬអនុរដ្ឋរបស់អ្នក។

ជំហាននេះគឺខុសគ្នា អាស្រ័យលើប្រភេទនៃការអប់រំដែលអ្នករៀន - ឧ. សាលា TAFE សាកលវិទ្យាល័យ។

ប៉ុន្តែអ្នកផ្តល់ការអប់រំទាំងអស់ត្រូវអនុលោមតាម DSE។

សូមមើលតារាងនៅទំព័រ 15 ដែលបង្ហាញពីអ្នកដែលអ្នកត្រូវយកតំអូញទៅជំរាបក្នុងជំហាននេះ។ ច្បាប់លើតំអូញនៃអ្នកផ្តល់ការអប់រំរបស់អ្នក ក៏គួរជួយក្នុងការនេះដែរ។ អ្នកអាចមើលក្នុងវែបសៃត៍របស់គេ ឬសុំគេយកមួយច្បាប់ក៏បាន។

បន្ទាប់ពីបានដាក់ពាក្យតំអូញហើយ អ្នកទទួល ឬអង្គការនឹងចាត់ការវា។ គេអាចទាក់ទងស្ថាប័នអប់រំជំនួសអ្នក។ គេក៏អាចណែនាំអោយធ្វើអ្វីផ្សេងទៀត ឬអោយរើសដំណោះស្រាយអ្វីមួយ។

## ជំរាបតំអូញទៅអ្នកណា

កំណត់សំគាល់: ឈ្មោះទាក់ទងខាងក្រោមនេះគ្រាន់តែការណែនាំប៉ុណ្ណោះ។ អាស្រ័យលើស្ថានភាពរបស់អ្នក អ្នកប្រហែលជាត្រូវទាក់ទងអ្នកផ្សេង។

| ឧទាហរណ៍នៃស្ថាប័នអប់រំ | ទាក់ទងអ្នកណា |
|---|---|
| សាលារដ្ឋ | ក្រសួងអប់រំក្នុងរដ្ឋឬអនុរដ្ឋរបស់អ្នក។ |
| សាលាក្រៅពីរដ្ឋ - កាតូលិក ឬឯករាជ្យ | អង្គការដែលទទួលរ៉ាប់រងសំរាប់សាលារបស់អ្នក - ឧ. គណៈកម្មាធិការសាលាសំរាប់សាលាឯករាជ្យ ឬសាលាកាតូលិកប្រចាំតំបន់។<br><br>បើរដ្ឋឬអនុរដ្ឋរបស់អ្នកមានអង្គការលើផ្នែកតំអូញសំរាប់សាលាក្រៅពីរដ្ឋ នោះអ្នកគួរទាក់ទងគេទៅ។ |
| សាលាអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈ (VET) – រាប់ទាំង TAFE | ក្រសួងរដ្ឋាភិបាលទទួលរ៉ាប់រងសំរាប់ការហ្វឹកហ្វឺននិងជំនាញក្នុងរដ្ឋឬអនុរដ្ឋរបស់អ្នក។<br><br>បើរដ្ឋឬអនុរដ្ឋរបស់អ្នកមានអង្គការលើផ្នែកតំអូញសំរាប់សាលា VET នោះអ្នកគួរទាក់ទងគេទៅ។ |
| សាកលវិទ្យាល័យ | ក្រុមប្រឹក្សា ឬគណៈកម្មាធិការសាកលវិទ្យាល័យ។<br><br>បើគេជួយមិនបាន អ្នកអាចទាក់ទងក្រសួងអប់រំរដ្ឋឬអនុរដ្ឋ។ |

ចូរកុំភ្លេចឆែកមើលថាអ្នកអាចដាក់ពាក្យតំអូញប្រភេទណាជាមួយសាលា។ សាលាទាំងអស់មិនដោះស្រាយប្រភេទតំអូញដូចគ្នានោះទេ។

## គំរូនៃដំណើរធ្វើតំអូញ

1. មើលរបៀបដាក់ពាក្យតំអូញរបស់ស្ថាប័ន

2. សំរេចចិត្តថានឹងដាក់ពាក្យតំអូញទៅអ្នកណា

3. ប្រមូលព័ត៌មានៈ

a) ដែលគេនឹងសួរចង់បាន

b) ដែលនឹងផ្តល់ភាពពិស្តារគ្រប់គ្រាន់

4. ផ្តោតទៅលើបារម្ភចំបងរបស់អ្នក

5. ជំរាបតំអូញហើយកត់ត្រាទុក

6. កត់ថ្ងៃសំខាន់ៗក្នុងសៀវភៅកំណត់ហេតុប្រចាំថ្ងៃ

7. រង់ចាំចំឡើយ

8. ព្យាយាមសំរុះសំរួលគ្នា

9. (បើមិនកើតទេ) គិតអំពីវិធីផ្សេងទៀត

## 3) ជំរាបតំអូញទោះអាជ្ញាធរផ្សេងទៀត

អ្នកអាចជំរាបតំអូញទៅអាជ្ញាធរផ្សេងទៀតបើអ្នកៈ

- មិនអាចដោះស្រាយបារម្ភរបស់អ្នកក្នុងជំហានពីមុន ហើយ/ឬ
- ជឿថាគេរើសអើងអ្នក។

### និយមន័យ: ការរើសអើង

ការរើសអើងពិការភាពគឺខុសច្បាប់ វាមានន័យថា:

- មនុស្សម្នាក់ត្រូវបានគេប្រព្រឹត្តមកលើយ៉ាងអាក្រក់ជាងពេលដែលគេមិនពិការ។
- មនុស្សម្នាក់ត្រូវធ្វើអ្វីមួយដែលគេមិនអាចធ្វើដោយព្រោះពិការភាពរបស់គេ ហើយការផ្លាស់ប្តូរក៏មិនមានទៀត។

អ្នកអាចស្វែងយល់ថែមទៀតក្នុងធនធានរបស់យើង: ពន្យល់ស្តង់ដារពិការភាពសំរាប់ការអប់រំ។

## គណៈកម្មការសិទ្ធិមនុស្សអូស្ត្រាលី (AHRC)

AHRC ជាអង្គការឯករាជ្យ។ វាស៊ើបអង្កេតតំអូញអំពីការរើសអើងខុសច្បាប់ក្រោម DDA ឬ DSE។

តើខ្ញុំដាក់ពាក្យតំអូញដូចម្តេច?

AHRC មានព័ត៌មានពីរបៀបដាក់ពាក្យតំអូញនៅវែបសៃត៍របស់គេ (https://humanrights.gov.au).

បើអ្នកមិនច្បាស់ថាអ្នកអាចដាក់ពាក្យតំអូញអំពីអ្វីមួយ អ្នកអាចទាក់ទងសេវាកម្មព័ត៌មានតំអូញនៃAHRC:

- តាមទូរស័ព្ទលេខ 1300 656 419
- តាមអ៊ីមេល infoservice@humanrights.gov.au.

## ភ្នាក់ងារប្រឆាំងនឹងការរើសអើងប្រចាំរដ្ឋនិងអនុរដ្ឋ

រដ្ឋនិងអនុរដ្ឋទាំងអស់មានច្បាប់ប្រឆាំងនឹងការរើសអើង និង/ឬ សិទ្ធិមនុស្ស និងឱកាសស្មើភាព។ អាស្រ័យលើកាលៈទេសៈរបស់អ្នក អ្នកអាចសំរេចចិត្តដាក់ពាក្យតំអូញក្រោមច្បាប់របស់រដ្ឋឬអនុរដ្ឋរបស់អ្នក។

សំរាប់ព័ត៌មានបន្ថែម សូមអញ្ជើញទៅមើលវែបសៃត៍ភ្នាក់ងារប្រឆាំងនឹងការរើសអើងសំរាប់រដ្ឋឬអនុរដ្ឋរបស់អ្នក។

សូមមើលឈ្មោះទាក់ទងរដ្ឋ អនុរដ្ឋ និងជាតិ (p. 21) សំរាប់តំណទៅវែបសៃត៍របស់គេ។

# អ្នកស៊ើបអង្កេតតំអូញ

ខំមិនវែល និងរដ្ឋ និងអនុរដ្ឋមានអ្នកស៊ើបអង្កេតដែលអាចជួយអ្នកក្នុងកាលៈទេសៈមានកំណត់។

## អ្នកស៊ើបអង្កេតប្រចាំរដ្ឋនិងអនុរដ្ឋ

អាស្រ័យលើស្ថានភាពរបស់អ្នក អ្នកអាចដាក់ពាក្យតំអូញទៅអ្នកស៊ើបអង្កេតតំអូញក្នុងរដ្ឋ ឬអនុរដ្ឋរបស់អ្នក។ គេអាចមើលថាតើតំអូញរបស់អ្នកត្រូវបានចាត់ការត្រឹមត្រូវឬអត់ក្នុងស្ថាប័នអប់រំរដ្ឋ។ យ៉ាងណាក៏ដោយ គេមិនអាចៈ

- ស៊ើបអង្កេតឬដោះស្រាយតំអូញលើការរើសអើងផ្ទាល់នោះទេ
- បដិសេធការសំរេចរបស់ស្ថាប័នអប់រំរបស់អ្នកឡើយ។

សំរាប់ព័ត៌មានបន្ថែម សូមអញ្ជើញទៅមើលវែបសៃត៍របស់អ្នកស៊ើបអង្កេតសំរាប់រដ្ឋឬអនុរដ្ឋរបស់អ្នក (សូមមើល ទ. 21 សំរាប់តំណទៅវែបសៃត៍)។

## អ្នកស៊ើបអង្កេតប្រចាំខំមិនវែល

បើអ្នកជាៈ

- សិស្ស VET ដែលទទួលប្រាក់កំចីនិស្សិត VET ឬ
- សិស្សអន្តរជាតិ រៀននៅស្ថាប័នអប់រំឯកជន។

នោះអ្នកអាចដាក់ពាក្យតំអូញទៅអ្នកស៊ើបអង្កេតខំមិនវែល។

គេអាចឆែកមើលថាតើតំអូញរបស់អ្នកត្រូវចាត់ការត្រឹមត្រូវឬអត់។ គេអាចណែនាំអោយដោះស្រាយតំអូញ។ យ៉ាងណាក៏ដោយ គេមិនអាចៈ

- ស៊ើបអង្កេតឬដោះស្រាយតំអូញលើការរើសអើងផ្ទាល់នោះទេ
- បដិសេធការសំរេចរបស់ស្ថាប័នអប់រំរបស់អ្នកឡើយ។

សំរាប់ព័ត៌មានបន្ថែម សូមអញ្ជើញទៅមើលវែបសៃត៍របស់អ្នកស៊ើបអង្កេតខំមិនវែល (សូមមើល ទ. 22 សំរាប់តំណទៅវែបសៃត៍)។

## ករណីសិក្សា: វ៉ែស្លី

វ៉ែស្លីខ្វាក់ភ្នែក ហើយកំពុងរៀននៅសាកលវិទ្យាល័យ។ គាត់ត្រូវបានផ្តល់មេរៀនដែលគាត់ទទួលមិនបាន។ តែបើទទួលបាន គាត់ត្រូវបានគេប្រគល់អោយមុនពេលគ្រប់គ្រាន់។

បន្ទាប់ពីទៅមកៗ គាត់ក៏ទៅគណៈកម្មាធិការសិទ្ធិមនុស្សអូស្ត្រាលី។ គេក៏ទាក់ទងទៅសាកលវិទ្យាល័យដើម្បីចរចារ។

តំអូញរបស់វ៉ែស្លីត្រូវបានដោះស្រាយបែបនេះ:

- សាកលវិទ្យាល័យយល់ស្របថានឹង:
  - ផ្តល់សំណេរអេលិចត្រូនិកបើអាចធ្វើបាន
  - ផ្តល់ប្រាក់ជំនួយចូលរួមសំរាប់ 60 ម៉ោងមួយឆមាស - ២. ដើម្បីជួយក្នុងការស្វែងរកនៅបណ្ណាល័យ
- វ៉ែស្លីយល់ស្របថានឹងប្រាប់សាកលវិទ្យាល័យអោយដឹងមេរៀនជាមុន។ គាត់នឹងប្រាប់គេ 8 សប្តាហ៍មុននឹងចាប់ផ្តើមឆមាស។

នេះជាការស្រង់មកពីក្តីសង្ខេបនៃករណីប្រវត្តិសាស្ត្រមួយ។ សូមមើលគណៈកម្មាធិការសិទ្ធិមនុស្សអូស្ត្រាលី (AHRC) (ឥតមានថ្ងៃទី) ការសំរបសំរួល DDA: ការអប់រំ វែបសែត៍ AHRC។

# កន្លែងទទួលជំនួយនិងព័ត៌មាន

អ្នកមិនបាច់ធ្វើអ្វីទាំងអស់ដោយខ្លួនឯងទេ។ អ្នកអាចសុំមិត្តភក្តិឬអ្នកជំនួយម្នាក់មកជួយអ្នករៀបចំការប្រជុំ ឬបំពេញហ្វម។ គេក៏អាចទៅប្រជុំជាមួយអ្នកផងដែរ។

បើអ្នកអាយុក្រោម 18 ឆ្នាំ អ្នកប្រហែលត្រូវការឪពុកម្តាយ អ្នកថែរក្សា ឬអាណាព្យាបាលស្របច្បាប់។

## ជំនួយលើការគាំទ្រ

អ្នកអាចទទួលជំនួយពីអ្នកមានវិជ្ជាជីវៈម្នាក់ពី**អ្នកគាំទ្រឯករាជ្យ**។
អ្នកអាចធ្វើដូច្នេះក្នុងដំណាក់ការណាក៏បាន។

### អ្នកគាំទ្រឯករាជ្យ

អ្នកគាំទ្រឯករាជ្យជាអ្នកដែលបានទទួលការហ្វឹកហ្វឺនឯកទេស
និងមានចំណេះឯកទេសដើម្បីជួយអ្នកដាក់ពាក្យតំអូញ។ គេអាចៈ

- ពន្យល់ដំណើរការអោយអ្នក
- ជួយអ្នកគិតអំពីគោលដៅរបស់អ្នក
- ជួយអ្នកខាងក្រដាសស្នាមនិងហ្វម
- ទៅប្រជុំជាមួយអ្នក
- ទាក់ទងអ្នកផ្តល់ការអប់រំជំនួសអ្នក។

មានសេវាកម្មគាំទ្រឥតគិតថ្លៃនិងតំលៃទាបជាច្រើនទូទាំងអូស្ត្រាលី ដែលអ្នកអាចរកអ្នកគាំទ្រឯករាជ្យបាន។
សូមស្វែងរកសេវាកម្មដែលត្រូវនឹងតំរូវការរបស់អ្នកនៅៈ

- អ្នកគាំទ្រពិការភាព (disabilitygateway.gov.au/legal/advocacy)
- បណ្តាញគាំទ្រពិការភាពអូស្ត្រាលី (dana.org.au/find-an-advocate)

## បណ្តាញមិត្ត

ការគាំទ្រសិទ្ធិរបស់អ្នកក្នុងការអប់រំអាចពិបាក។
វាអាចជួយអ្នកបើអ្នកមានមិត្តដែលធ្លាប់ឆ្លងកាត់ការដូចគ្នានេះពីមុន។

បណ្តាញមិត្តអាចជាប្រភពនៃៈ

- ការយល់ដឹង
- ជំនួយដល់មនោសញ្ចេតនា
- ឱវាទ
- ព័ត៌មាន
- ការទាក់ទងក្នុងសង្គមជាមួយអ្នកណាម្នាក់ដែល'យល់'។

គេអាចត្រូវការទីកន្លែងណាមួយ ឬការជួបទល់មុខ – ឬអាចជាមិនត្រូវការ។
អ្នកអាចទាក់ទងជាមួយមនុស្សក្នុងរបៀបដែលអ្នកពេញចិត្ត។ ឧ. ទល់មុខ មិនទល់មុខ តាមសារ តាមវិឌីអូ ។ល។

ដើម្បីចាប់ផ្តើម អ្នកអាចឆែកមើលវែបសៃត៍ ឬប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់យុវជន ឬអង្គការពិការភាព។ អាចមានក្លឹប ឬព្រឹត្តិការណ៍ក្នុងសហគមន៍ ឬនៅស្ថាប័នអប់រំរបស់អ្នក។

## ជំនួយលើការទាក់ទង

| សេវាកម្មបកប្រែនិងបកប្រែផ្ទាល់មាត់ | សេវាកម្មបញ្ជូនតប្រចាំជាតិ | សេវាកម្មបកប្រែឥតគិតថ្លៃ |
|---|---|---|
| គេអាចជួយបានបើអ្នកមិនចេះនិយាយភាសាអង់គ្លេស។<br><br>ទូរស័ព្ទ: **131 450**<br><br>វែបសៃត៍: https://www.tisnational.gov.au | គេអាចជួយបានបើអ្នកត្រូវការសំឡេងទៅសារ សារទៅសំឡេង Auslan ទៅអង់គ្លេស ឬអង់គ្លេសទៅAuslan ។<br><br>ទូរស័ព្ទ: **1300 555 727** (និយាយនិងស្តាប់)<br><br>វែបសៃត៍:https://www.accesshub.gov.au | គេអាចបកប្រែឯកសារសំខាន់ផ្ទាល់ខ្លួន។<br>សូមទៅមើលវែបសៃត៍ដើម្បីអោយបានដឹងថានរណាអាចប្រើសេវាកម្មនេះបាន។<br><br>ទូរស័ព្ទ: **1800 962 100**<br><br>វែបសៃត៍: https://translating.homeaffairs.gov.au |

## ជំនួយលើការរស់នៅ

អ្នកគួររកជំនួយក្នុងពេលដែលអ្នកគិតថាអ្នកប្រហែលត្រូវការជំនួយ។
អ្នកមិនចាំបាច់ចាំដល់មានវិបត្តិទេមុននឹងសួររកជំនួយ។
អ្នកជំនួយផ្នែកសុខភាពផ្លូវចិត្តនិងការអោយឱវាទ ( ទូរស័ព្ទ សារ និងតាមវែបសៃត៍ ):

- មូលនិធិ Blue Knot (https://blueknot.org.au)
- លែហ្វ៍ឡាញ (https://www.lifeline.org.au)
- ប៊ីយ៉ន់ប្លូ (https://www.beyondblue.org.au)
- Yarning Safe'N'Strong (https://www.vahs.org.au/yarning-safenstrong)
- QLife (https://qlife.org.au)
- លេខទូរស័ព្ទជំនួយសំរាប់កុមារ (https://kidshelpline.com.au)
- បណ្តាញគាំទ្រយុវជនវប្បធម៌ចំរុះ (https://myan.org.au)
- LGBTIQ+ សុខភាពអូស្ត្រាលី (https://www.lgbtiqhealth.org.au/disability_inclusion)

## ព័ត៌មាននិងជំនួយពិការភាព

- សហព័ន្ធនៃអង្គការពិការភាពអូស្ត្រាលី (https://www.afdo.org.au)
- កុមារនិងយុវជនពិការនៅអូស្ត្រាលី (https://www.cyda.org.au)
- មជ្ឈមណ្ឌលពិការភាពអូស្ត្រាលី(https://www.disabilityaustraliahub.com.au)
- ច្រកផ្លូវពិការភាព (https://www.disabilitygateway.gov.au)
- បណ្តាញពិការភាពជនជាតិដើម (https://fpdn.org.au)
- ការរួមបញ្ចូលអូស្ត្រាលី (https://www.inclusionaustralia.org.au)
- សម្ព័ន្ធពិការភាពជាតិសាសន៍ (https://www.neda.org.au)
- ជនមានពិការភាពនៅអូស្ត្រាលី (https://pwd.org.au)
- ស្ត្រីមានពិការភាពនៅអូស្ត្រាលី (https://wwda.org.au)

## ជំនួយខាងផ្លូវច្បាប់

- ច្រកផ្លូវពិការភាព (https://www.disabilitygateway.gov.au/legal/legal-services)
- មជ្ឈមណ្ឌលច្បាប់សហគមន៍អូស្ត្រាលី (https://clcs.org.au/legal-help)
- មជ្ឈមណ្ឌលការងារច្បាប់ឥតគិតថ្លៃអូស្ត្រាលី (https://www.probonocentre.org.au/legal-help)
- ច្បាប់យុវជនអូស្ត្រាលី (https://yla.org.au)

## ឈ្មោះទាក់ទងប្រចាំរដ្ឋ អនុរដ្ឋ និងជាតិ

| រដ្ឋ/អនុរដ្ឋ | ក្រសួងអប់រំ | អ្នកស៊ើបអង្កេតតំអូញ | គណៈកម្មការសិទ្ធិមនុស្ស |
|---|---|---|---|
| អនុរដ្ឋរាជធានីអូស្ត្រាលី (ACT) | នាយកដ្ឋានអប់រំ ACT: https://www.education.act.gov.au | https://www.ombudsman.act.gov.au | https://hrc.act.gov.au |
| ញូសៅវែលស៍ (NSW) | ក្រសួងអប់រំនៃរដ្ឋាភិបាលញូសៅវែលស៍: https://education.nsw.gov.au | https://www.ombo.nsw.gov.au | https://antidiscrimination.nsw.gov.au |

| | | | |
|---|---|---|---|
| អនុរដ្ឋខាងជើង(NT) | ក្រសួងអប់រំនៃរដ្ឋាភិបាល NT: https://education.nt.gov.au | https://www.ombudsman.nt.gov.au | https://adc.nt.gov.au |
| ឃ្វីនសាឡែន | ក្រសួងអប់រំឃ្វីនសាឡែន: https://education.qld.gov.au | https://www.ombudsman.qld.gov.au | https://www.qhrc.qld.gov.au |
| អូស្ត្រាលីខាងត្បូង | ក្រសួងសំរាប់អប់រំអូស្ត្រាលីខាងត្បូង: https://www.education.sa.gov.au | https://www.ombudsman.sa.gov.au | https://www.equalopportunity.sa.gov.au |
| ថៃសមេនា | ក្រសួងសំរាប់អប់រំកុមារនិងយុវជនថៃសមេនា: https://www.decyp.tas.gov.au | https://www.ombudsman.tas.gov.au | https://equalopportunity.tas.gov.au/home |
| វិចតូរៀ | ក្រសួងអប់រំវិចតូរៀ: https://www.education.vic.gov.au | https://www.ombudsman.vic.gov.au | https://www.humanrights.vic.gov.au |
| អូស្ត្រាលីខាងលិច | ក្រសួងអប់រំអូស្ត្រាលីខាងលិច: https://www.education.wa.edu.au | https://www.ombudsman.wa.gov.au | https://www.wa.gov.au/organisation/equal-opportunity-commission |
| ជាតិ | ក្រសួងអប់រំនៃរដ្ឋាភិបាលអូស្ត្រាលី: https://www.education.gov.au | អ្នកស៊ើបអង្កេតខំមិនវែល: https://www.ombudsman.gov.au<br>និស្សិតអន្តរជាតិ: https://www.ombudsman.gov.au/complaints/international-student-complaints | គណៈកម្មាធិការសិទ្ធិមនុស្ស: https://humanrights.gov.au/complaints/make-complaint |

https://www.education.gov.au/disability-standards-education-2005/information-resources-students-disability-and-their-caregivers